ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ...២៣៧៩...អពដ

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង
# ស្តីពី
# ការប្រើប្រាស់មធ្យោបាយជូនដំណឹង
# តាមប្រព័ន្ធអេឡិកត្រូនិកដល់អ្នកជាប់ពន្ធ

អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូន លោកឧកញ៉ា លោក-លោកស្រី ជាអភិបាល ឬបណ្ណាធិការសហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសមេត្តាជ្រាបដូចខាងក្រោម ÷

អនុលោមតាមវាក្យខណ្ឌ ខ នៃកថាខណ្ឌ១ នៃមាត្រា៩១ និងកថាខណ្ឌ៣ នៃមាត្រា៩២ នៃច្បាប់ស្តីពីសារពើពន្ធ ដែលចែងអំពីសិទ្ធិទទួលព័ត៌មានរបស់អ្នកជាប់ពន្ធនិងកាតព្វកិច្ចរបស់រដ្ឋបាលសារពើពន្ធក្នុងការផ្តល់ព័ត៌មានដល់អ្នកជាប់ពន្ធ អគ្គនាយកដ្ឋានពន្ធដារនឹងដាក់ឱ្យដំណើរការនូវប្រព័ន្ធជូនដំណឹង (Notification System) នូវព័ត៌មានដែលទាក់ទិននឹងការបំពេញកាតព្វកិច្ចសារពើពន្ធជាអាទិ៍មាន ការជូនដំណឹងអំពីពេលវេលាដាក់លិខិតប្រកាសសារពើពន្ធ ពេលវេលាបង់ពន្ធ ការកំណត់ពន្ធ ឬព័ត៌មានផ្សេងទៀតតាមរយៈសារអេឡិកត្រូនិកជា E-Mail ឬ SMS ទៅកាន់ទូរស័ព្ទដៃរបស់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសបន្ថែមពីលើយន្តការដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន ។ អគ្គនាយកដ្ឋានពន្ធដារនឹងរៀបចំធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ (Taxpayer's Information) ជាពិសេសអាសយដ្ឋានសារអេឡិកត្រូនិក និងលេខទូរស័ព្ទ ដើម្បីឱ្យការបញ្ជូនព័ត៌មានប្រព្រឹត្តទៅដោយរលូននិងមានប្រសិទ្ធភាព។

អាស្រ័យហេតុនេះសូមលោកឧកញ៉ា លោក-លោកស្រី ជាអភិបាលឬបណ្ណាធិការសហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស មេត្តាជ្រាបជាព័ត៌មាននិងរួមសហការជាមួយអគ្គនាយកដ្ឋានពន្ធដារក្នុងការធ្វើបច្ចុប្បន្នភាពដូចបានជម្រាបជូនខាងលើ។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមជឿជាក់ថា ការដាក់ឱ្យដំណើរការប្រព័ន្ធជូនដំណឹងនេះនឹងជួយសម្រួលដល់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ក្នុងការទទួលព័ត៌មានផ្សេងៗពីរដ្ឋបាលសារពើពន្ធបានងាយស្រួលគ្រប់ទីកន្លែង និងទាន់ពេលវេលា ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារ

**គង់ វិបុល**

ចម្លងជូន ÷
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
  ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ដើម្បីជូនជ្រាប)
- ឯកសារ-កាលប្បវត្តិ